# សេចក្តីប្រកាសព័ត៌មាន

**ការប្រគំតន្ត្រីសម័យផ្សព្វផ្សាយការយល់ដឹងអំពី ការការពារនិងគ្រប់គ្រងធនធានព្រៃឈើ ក្រោមកម្មវិធីជាតិកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើកម្ពុជា**

**(រេដ+)**

កម្មវិធីជាតិរេដ+កម្ពុជា នឹងរៀបចំការការប្រគំតន្ត្រីមួយ នៅថ្ងៃសៅរ៍ ទី២២ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោង០៥ល្ងាច ដល់ម៉ោង៩:៣០យប់ នៅមជ្ឈមណ្ឌលកោះពេជ្រ ។

កម្មវិធីប្រគំតន្ត្រីនេះ រៀបចំឡើងដោយមានកិច្ចសហការជាមួយ ក្រុមហ៊ុន i-Click និងSmart mobile និងកម្មវិធី UN-REDD ដែលរួមមាន អង្គការកសិកម្មស្បៀងអាហារនៃសហប្រជាជាតិ(FAO), កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) មានគោលបំណងផ្សព្វផ្សាយនិងបង្កើនការយល់ដឹងពីទំនាក់ទំនងនៃបម្រែបម្រួលអាកាសធាតុ និងភាពក្រីក្រ តម្លៃ និងសារប្រយោជន៍របស់ព្រៃឈើ កិច្ចការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើឲ្យបានត្រឹមត្រូវ និងរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុនៅលើពិភពលោក។

ការប្រគំតន្ត្រីនេះ មានការចូលរួម សម្តែងពីតារាចម្រៀងល្បីៗមួយចំនួន ដូចជា ............... ។ ក្នុងនោះដែរ នឹងមានការ បញ្ចាំងវីដេអូអំពី រេដ+ ការប្រកាសលទ្ធផល និងប្រគល់រង្វាន់ ដល់ជ័យលាភី នៃការប្រកួតរូបថត ការដាក់តាំងពិព័ណ៌រូបថតដែលឈ្នះ និងការតាំងលក់ទំនិញមួយចំនួនមកពីក្រុមហ៊ុន Canon និង Smart Mobile។

កម្មវិធីនេះ នឹងមានការអញ្ជើញចូលរួម បើកកម្មវិធីដោយមន្ត្រីជាន់ខ្ពស់នៃ រដ្ឋបាលព្រៃឈើ និងបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងៗ និងតំណាងក្រុមហ៊ុន និងអង្គការដៃគូ។

-30-

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

ទូរស័ព្ទលេខ៖ +៨៥៥ ២៣ ២២៤ ២៥១ ឬ +៨៥៥ ១២ ៥០០ ៩២២

អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org

គេហទំព័រ៖ http://www.cambodia-redd.org/category/document-centre/photo-contest

ឬទៅកាន់ទីតាំងការិយាល័យលេខាធិការដ្ឋានរេដ+ ដែលមានទីតាំងនៅតាមអាស័យដ្ឋាន ផ្ទះលេខ៤០ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលស្ថិតនៅក្នុងរដ្ឋបាលព្រៃឈើ ជាន់ទី៣។